**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ.០៤៦២១..អ.បស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៧ ឆ្នាំ២០០៩

# សារាចរណែនាំ

## ស្ដីពី

## ការផ្ដល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យ

## ជូនភោជនីយដ្ឋាន_អាហារដ្ឋាន

**១០៩**

- យោងសារាចរលេខ ០៣៣០អបស/ឱអបស ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ របស់ក្រសួងសុខាភិបាល ស្ដីពីលក្ខខណ្ឌអនាម័យអាហារដ្ឋាន-ភោជនីយដ្ឋាន
- យោងសារាចរលេខ ០០៣ សរណន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ របស់ក្រសួងទេសចរណ៍ ស្ដីពីការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋាន.

ដើម្បីគ្រប់គ្រងការផ្ដល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ភោជនីយដ្ឋាន-អាហារដ្ឋាន អោយបានល្អប្រសើរ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

១. ការផ្ដល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋានខ្នាតធំ ភោជនីយដ្ឋានខ្នាតមធ្យម Bar Bistro និងអាហារដ្ឋានទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងសុខាភិបាលតាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

២. ការផ្ដល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋានខ្នាតតូច ភោជនីយដ្ឋានបៀរហ្គាដិន និងអាហារដ្ឋានក្នុងស្រុក ត្រូវដាក់ពាក្យស្នើសុំនៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត។

៣. បែបបទក្នុងការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់លើអនាម័យត្រូវអនុវត្តដូចតទៅ :
- ពាក្យស្នើសុំមានបិទតែមប្រិ៍ ១.០០០រៀល (មានគំរូ)
- ជីវប្រវត្តិសង្ខេបរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន/អាហារដ្ឋាន (មានគំរូ)
- អត្តសញ្ញាណប័ណ្ណថតចំលង ឬលិខិតឆ្លងដែនថតចំលង (ក្នុងករណីជាជនបរទេស) របស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន-អាហារដ្ឋាន
- វិញ្ញាបនប័ត្រសុខភាពរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងភោជនីយដ្ឋាន-អាហារដ្ឋាន ចេញដោយក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត
- លិខិតបញ្ជាក់ដាក់ទីតាំងភោជនីយដ្ឋាន-អាហារដ្ឋាន ដែលចេញដោយអាជ្ញាធរមូលដ្ឋាន (ឃុំ/សង្កាត់)
- រូបថត (ថតចំពីមុខភោជនីយដ្ឋាន-អាហារដ្ឋាន បន្ទប់បរិភោគ បន្ទប់ចំអិនចំណីអាហារ បន្ទប់រៀបចំចំណីអាហារ បន្ទប់លាងចាន និងសំភារៈផ្សេងៗ បន្ទប់ទឹក និងបង្គន់អនាម័យ)។

៤. ក្រសួងសុខាភិបាលនឹងផ្តល់ចម្លើយអំពីការផ្តល់វិញ្ញាបនប័ត្របញ្ជាក់លើអនាម័យ ក្នុងការសុំបើក សុំប្តូរទីតាំង និង សុំផ្លាស់ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋាន ដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ យ៉ាងយឺតបំផុតរយៈពេល៣០ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលសំណុំលិខិតគ្រប់គ្រាន់ ។

ទទួលបាននូវសារាចរណែនាំនេះ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវសហការជាមួយ សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយណែនាំអោយបានទូលំទូលាយដល់ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន ក្នុងការអនុវត្តន៍អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម៉ម_ប៊ុនហេង

ចំលងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងទេសចរណ៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- គ្រប់សាលារាជធានី-ខេត្ត
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- អគ្គនាយកបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- ឯកសារ និងកាលប្បវត្តិ